



Disability Services Commissioner

# គ្មានបញ្ហាអ្វីទេ

## ក្នុងការធ្វើបណ្តឹង

It's OK to Complain - **Cambodian**

## ទំរង់ព័ត៌មានដែលមាន

សូមទាក់ទងការិយាល័យរបស់ស្នងការសេវាកម្មពិការភាព (Commissioner) ដើម្បីទទួលព័ត៌មានតាមទំរង់ដែលមាន។

## ដើម្បីធ្វើបណ្តឹង

លោកអ្នកអាចធ្វើបណ្តឹងទៅកាន់ Commissioner តាមរយៈ:

- ការសរសេរ
- ទូរស័ព្ទ
- ការផ្ញើទូរសារ
- ការដាក់ពាក្យបណ្តឹងតាមរយៈវ៉ិបសៃ
- ឬតាមរយៈវិធីឯទៀតដែលសមរម្យទៅតាមកាលៈទេសៈរបស់លោកអ្នក

## ដើម្បីទទួលព័ត៌មានបន្ថែម

Disability Services Commissioner
Level 30, 570 Bourke Street
Melbourne Vic 3000

**ទូរស័ព្ទ**
បណ្តឹង
១៨០០ ៦៧៧ ៣៩២ (ឥតគិតថ្លៃ)
ការសាកសួរទូទៅ
១៣០០ ៧២៨ ១៨៧ (ថ្លៃទូរស័ព្ទក្នុងតំបន់)

**TTY** ១៣០០ ៧២៦ ៥៦៣

**ទូរសារ** ០៣ ៨៦០៨ ៥៧៦៥

**Website** www.odsc.vic.gov.au





## តើលោកអ្នកត្រូវការជំនួយខ្លះដើម្បីដោះស្រាយបណ្ដឹងអំពីសេវាពិការភាព ឬស្ថាប័នផ្ដល់សេវា ឬទេ?

Commissioner សេវាពិការភាព (Commissioner) អាចផ្ដល់សេវាលាក់ការសម្ងាត់ និងឥតគិតថ្លៃ ដើម្បីជួយលោកអ្នក។

វាមានផលប្រយោជន៍ច្រើនក្នុងការធ្វើបណ្ដឹងទៅកាន់ស្ថាប័នផ្ដល់សេវាពិការភាពរបស់លោកអ្នក និងក្នុងការរកដំណោះស្រាយឲ្យបានរហ័សតាមលទ្ធភាព។

ជាផ្នែកនៃច្បាប់ពិការភាព ២០០៦ ស្ថាប័នផ្ដល់សេវាពិការភាពទាំងអស់ត្រូវមានដំណើរការគ្រប់គ្រងបណ្ដឹងនៅក្នុងស្ថាប័ន ដូច្នេះជាការមានប្រយោជន៍ក្នុងការសាកសួរអំពីដំណើរការនេះដើម្បីជួយកំណត់វិធីល្អបំផុតក្នុងការដោះស្រាយបណ្ដឹងលោកអ្នក។

ដំណើរការបណ្ដឹងអាចបណ្ដាលឲ្យមានសេវាកាន់តែប្រសើរឡើងសំរាប់អ្នកមានពិការភាពនៅក្នុងរដ្ឋវិចតូរីយ៉ា ដូច្នេះការរកដំណោះស្រាយរួមគ្នាគឺមានភាពប្រសើរសំរាប់ជនរាល់រូប។

## អ្នកណានៅដែលអាចធ្វើបណ្ដឹងបាន?

ជនរាល់រូបអាចធ្វើបណ្ដឹងអំពីសេវាពិការភាពទៅកាន់ Commissioner។

ជនទាំងអស់នេះមានរួមទាំងអ្នកមានពិការភាព គ្រួសារនិងអ្នកថែទាំរបស់អ្នកនោះ បុគ្គលិកធ្វើការនៅក្នុងសេវាពិការភាព និងជនណាមួយផ្សេងទៀតដែលមានបំណងធ្វើបណ្ដឹង។

## តើបណ្ដឹងអាចអំពីអ្វីនៅ?

បណ្ដឹងអាចធ្វើទៅកាន់ Commissioner អំពី:

- ការផ្ដល់សេវាពិការភាព
- វិធីដែលស្ថាប័នផ្ដល់សេវាពិការភាពបានគ្រប់គ្រងបណ្ដឹងអំពីសេវាពិការភាព។

## តើ Commissioner សេវាពិការភាពធ្វើអ្វីនៅ?

Commissioner ត្រូវបានបង្កើតឡើងដើម្បីធ្វើការជាមួយអ្នកមានពិការភាព និងស្ថាប័នផ្ដល់សេវាពិការភាព ដើម្បីដោះស្រាយបណ្ដឹង។

Commissioner ជំរុញទឹកចិត្តនិងជួយរកដំណោះស្រាយបណ្ដឹងតាមវិធីផ្សេងៗគ្នា ដោយមានរួមទាំងកិច្ចពិភាក្សាក្រៅផ្លូវការ, ដំណើរការសំរុះសំរួល, ឬការស៊ើបអង្កេតផ្លូវការនៅក្នុងកាលៈទេសៈខ្លះ។

Commissioner បានចាប់ផ្ដើមនៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០០៧ នៅក្រោមច្បាប់ពិការភាព ២០០៦ ដើម្បីកែលំអសេវាសំរាប់អ្នកមានពិការភាពក្នុងរដ្ឋវិចតូរីយ៉ា។

Commissioner គឺជាអ្នកឯករាជដាច់ចេញពីរដ្ឋាភិបាល Department of Human Services (ក្រសួងសេវាពលរដ្ឋ) និងស្ថាប័នផ្ដល់សេវាពិការភាព។

